**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ**

*ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម*

# របាយការណ៍
# ស្តីពីការចុះកិច្ចសន្យាផលិតកម្មកសិកម្ម(CONTRACT FARMING) ផលិតនិងផ្គត់ផ្គង់ស្រូវ និងដំឡូងមី សរីរាង្គរវាងសហគមន៍កសិកម្មក្នុងខេត្តព្រះវិហារ ជាមួយក្រុមហ៊ុនឯកជន ក្នុងឆ្នាំ២០១៨

## ១.ស្ថានភាពទូទៅសហគមន៍កសិកម្មក្នុងខេត្តព្រះវិហារ

ខេត្តព្រះវិហារ ជាខេត្តមួយមានទីតាំងស្ថិតនៅប៉ែកខាងជើងនៃប្រទេសកម្ពុជា ដែលមានចំងាយ២៩៤ គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងត្បូងជាប់ខេត្តកំពង់ធំ ខាងលិចជាប់ជាមួយខេត្តសៀមរាប និងឧត្តមានជ័យ ខាងកើតជាប់ខេត្តស្ទឹងត្រែង ខាងជើងជាប់ជាមួយប្រទេសថៃ និងប្រទេសឡាវ។ បច្ចុប្បន្នប្រជាជនក្នុងខេត្តភាគច្រើនប្រកបរបរកសិកម្ម ដោយដំណាំសំខាន់រួមមានៈ ស្រូវ ដំឡូងមី សណ្តែកសៀង សណ្តែកបាយ។ល។ បន្ថែមនឹងគោលនយោបាយពង្រឹងលើការនាំអង្ករចេញ រដ្ឋាភិបាលបានបង្កើតច្បាប់ស្តីពីសហគមន៍កសិកម្មដើម្បីជួយលើកកំពស់ជីវភាពកសិករ តាមរយៈការប្រកបមុខបរកសិកម្ម ការប្រមូលទិញ-លក់លក្ខណៈជាក្រុម ឬជាលក្ខណៈតាមបែបកិច្ចសន្យាសម្រាប់ជួយកាត់បន្ថយការឆ្លៀតឱកាសកេងប្រវ័ញ្ចលើកសិករ ពីសំណាកឈ្មួញកណ្តាល។

បច្ចុប្បន្ននេះខេត្តព្រះវិហារមានសហគមន៍កសិកម្មសរុបចំនួន ៤៣សហគមន៍ ដែលមានការសម្របសម្រួលដោយការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម និងត្រូវបានចុះបញ្ជីទទួលស្គាល់ជាសហគមន៍កសិកម្មស្របច្បាប់ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ។ ក្នុងឆ្នាំ២០១៨នេះ សហគមន៍កសិកម្មទូទាំងខេត្តមានសមាជិកសរុប9,285នាក់(ស្ត្រី6,070នាក់) ភាគហ៊ុនសរុបមាន3,175,210,00 (ប្រមាណជាUSD793,877) និងទុនជាសាច់ប្រាក់ចំនួន5,473,609,000រៀល(ប្រមាណជាUSD1,368,402)។ ក្នុងនោះដែរមុខរបរសំខាន់ៗរបស់សហគមន៍កសិកម្ម ផ្តោតលើការធ្វើឥណទានសាច់ប្រាក់ ផ្គត់ផ្គង់សម្ភារៈកសិកម្ម ការប្រើប្រាស់សេវារួមគ្នា ចែកចាយទឹកស្អាត និងទីផ្សារស្រូវ-ដំឡូងមីសរីរាង្គ។

## ២.បរិមាណនិងសកម្មភាពរបស់សហគមន៍ក្នុងការផលិត និងផ្គង់ស្រូវសរីរាង្គក្នុងឆ្នាំ២០១៨

យោងទៅតាមលក្ខខ័ណ្ឌអំណោយផល ប្រជាកសិករក្នុងខេត្តព្រះវិហារភាគច្រើនដាំដំណាំមិនប្រើប្រាស់ជី និងសារធាតុគីមីផ្សេងៗ ពិសេសគឺដំណាំស្រូវ និងដំឡូងមី ជាហេតុបង្កលក្ខណៈងាយស្រួលក្នុងការអនុវត្តលើដំណាំសរីរាង្គ។ ខណៈដែលខេត្តមានសក្តានុពលខាងលើទើបមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ(PDAFF-PVH) និងគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវ-អង្ករកម្ពុជា(SCCRP) នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិធ្វើការ គាំទ្រនិងសហការណ៍គ្នាយ៉ាងជិតស្និទលើការងារសម្របសម្រួលអោយក្រុមហ៊ុនឯកជន និងសហគមន៍កសិកម្មបានជួបចចារគ្នាក្នុងការផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គ។

នៅឆ្នាំ២០១៣ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ និងគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវ-អង្ករកម្ពុជា(SCCRP) នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិបានសហការគ្នាសម្របសម្រួលអោយសហគមន៍កសិកម្មចំនួន៥ បានចុះកិច្ចសន្យាផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គបាន ចំនួន៥៥០តោន និងមានអ្នកផលិតចំនួន១០០នាក់។

រហូតមកដល់ឆ្នាំ២០១៨នេះ មានសហគមន៍កសិកម្មចំនួន៣២ បានចុះកិច្ចសន្យាផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គសរុប ***26,786.25*** តោន(ស្រូវក្រអូប 9,585.72តោន, ស្រូវស17,200.53តោន) ដែលមានសមាជិកផលិតសរុបចំនួន***5,053គ្រួសារ*** លើផ្ទៃដីសរុប ***16,052.01ហិចតា*** សម្រាប់លក់អោយក្រុមហ៊ុនចំនួន០៤គឺៈ ក្រុមហ៊ុនអេមរ៉ាយ (AMRU Rice) ក្រុមហ៊ុនអាហ្គ្រោអង្គរអ៊ីនធើត្រេដ(Agro Angkor Inter Trade) ក្រុមហ៊ុន ស៊ិកនេតឈ័រអេហ្សអេស៊ា (Signatures of Asia) និងក្រុមហ៊ុនសាជីវកម្មសហគមន៍កសិកម្មកម្ពុជា(CACC)។

**ក្រៅពីផលិតស្រូវរីរាង្គខាងលើ** មានសហគមន៍៨ ក្នុងចំណោមសហគមន៍ផលិតស្រូវសរីរាង្គបានចុះកិច្ចសន្យាផលិត និងផ្គត់ផ្គង់ជំឡូងមីសរីរាង្គអោយក្រុមហ៊ុនសាជីវកម្មសហគមន៍កសិកម្មកម្ពុជា សរុបចំនួន ***10,748តោន*** មានសមាជិកផលិតចំនួន ***577គ្រួសារ*** និងមានផ្ទៃដីផលិតសរុប ***789.01ហិចតា***។

**តារាងសង្ខេបបរិមាណកិច្ចសន្យាផលិតស្រូវសរីរាង្គ**

| ល.រ | សហគមន៍កសិកម្ម | ក្រុមហ៊ុន | អ្នកផលិត (គ្រួសារ) | កិច្ចសន្យាស្រូវក្រអូប(តោន) | កិច្ចសន្យាស្រូវស(តោន) | កិច្ចសន្យាសរុប(តោន) |
|---|---|---|---|---|---|---|
| 1 | 17 សហគមន៍កសិកម្ម | អេរ៉ាយ | 2,748 | 6,506.32 | 8,466.13 | 14,972.45 |
| 2 | 06 សហគមន៍កសិកម្ម | អាហ្គ្រោអង្គរ | 1,053 | 2,383.6 | 4,843 | 7,226.6 |
| 3 | 08 សហគមន៍កសិកម្ម | ស៊ិកណេតឈ័រ | 1,067 | 494.8 | 3,053.4 | 3,548.2 |
| 4 | 01 សហគមន៍កសិកម្ម | CACC | 185 | 201 | 839 | 1,040 |
| សរុប | | | 5,053 | 9,585.72 | 17,200.53 | 26,786.25 |

**តារាងសង្ខេបបរិមាណកិច្ចសន្យាផលិតជំឡូងមីសរីរាង្គ**

| ល.រ | សហគមន៍កសិកម្ម | ក្រុមហ៊ុន | អ្នកផលិត (គ្រួសារ) | កិច្ចសន្យាជំឡូងមី(តោន) |
|---|---|---|---|---|
| 1 | 08សហគមន៍កសិកម្ម | CACC | 577 | 10,748 |

## I. ខ្លឹមសារសំខាន់ៗនៅក្នុងកិច្ចសន្យាផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គមានដូចខាងក្រោមៈ

1. យោងតាមកិច្ចសន្យាចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ រវាងក្រុមហ៊ុន**អេមរុ រ៉ាយស៍ ខេមបូឌា** (AM RU RICE Cambodia CO.,LTD) ជាមួយសហគមន៍កសិកម្មចំនួន១៧ ដែលជាសមាជិកសហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ ដើម្បីធ្វើកិច្ចព្រមព្រៀងផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គសរុបចំនួន **14,972.45**តោន(ស្រូវក្រអូប **6,506.32**តោន, ស្រូវស**8,466.13**តោន) មានសមាជិកផលិតចំនួន **2,748**គ្រួសារ និងមានផ្ទៃដីផលិតសរុប 9,148.81ហិចតា។

## ក.តារាងលំអិតតាមសហគមន៍នីមួយៗ៖

| | ឈ្មោះសហគមន៍កសិកម្ម | ស្រុក | សមាជិកផលិត (គ្រួសារ) | ផ្ទៃដីសរុប (ហ.ត) | ស្រូវក្រអូប (តោន) | ស្រូវសរ (តោន) | ចំនួនកិច្ចសន្យាសរុប (ត) |
|---|---|---|---|---|---|---|---|
| ១ | ក្របៅពព្រហ្មទេព | គូលែន | 142 | 587 | 466.7 | 546.4 | 1,0131.1 |
| ២ | កែលំអរជីវភាពរសនៅ | ត្បែងមានជ័យ | 102 | 438.4 | 223.8 | 287 | 510.8 |
| ៣ | សាមគ្គីរហ័សមានជ័យ | រវៀង | 111 | 252.52 | 180.5 | 72.4 | 252.9 |
| ៤ | លើកកំពស់ស្ត្រី | រៀង | 523 | 1,826.23 | 1,076.2 | 1,789.5 | 2,865.7 |
| ៥ | រំដួលម្លូព្រៃជាយដែន | ឆែប | 204 | 675.31 | 536.2 | 562.65 | 1,098.85 |
| ៦ | ស្ត្រីរតនៈ | ជ័យសែន | 496 | 2,197.15 | 3,147.92 | 1,781.98 | 4,929.9 |
| ៧ | តស៊ូសែនជ័យ | ជ័យសែន | 164 | 621.8 | 836.5 | 335 | 1,171.5 |
| ៨ | ប្រមេសែនជ័យ | ត្បែងមានជ័យ | 88 | 281.5 | 0 | 322.5 | 322.5 |
| ៩ | ជាំក្សាន្តជាយដែនមានជ័យ | ជាំក្សាន្ត | 225 | 628.5 | 3 | 683.2 | 686.2 |
| ១០ | រំដោះស្រែសាមគ្គីមានជ័យ | ជាំក្សាន្ត | 66 | 132.5 | 0 | 163.5 | 163.5 |
| ១១ | ទឹកក្រហមកែលំអរជីវភាព | ជាំក្សាន្ត | 108 | 256.5 | 3.5 | 388.3 | 391.8 |
| ១២ | រអាងរួមគ្នាអភិវឌ្ឍន៍ | សង្គមថ្មី | 74 | 170.8 | 0 | 176.9 | 176.9 |
| ១៣ | ព្រះឃ្លាំងមានជ័យ | ត្បែងមានជ័យ | 46 | 67.5 | 0 | 104.9 | 104.9 |
| ១៤ | អភិវឌ្ឍន៍កូនខ្មែរជំនាន់ក្រោយ | ត្បែងមានជ័យ | 99 | 260.5 | 32 | 256.5 | 288.5 |
| ១៥ | រណោះសិរ្យព្រះខ័នអភិវឌ្ឍន៍ | សង្គមថ្មី | 111 | 257.15 | 0 | 251 | 251 |
| ១៦ | ត្បែងពីរសាមគ្គីរីកចំរើន | គូលែន | 123 | 400.6 | 0 | 632.6 | 632.6 |
| ១៧ | ស្តៅអភិវឌ្ឍន៍ | សង្គមថ្មី | 66 | 94.85 | 0 | 111.8 | 111.8 |
| សរុប | | | 2,748 | 9,148.81 | 6,506.32 | 8,466.13 | 14,972.45 |

## ខ/. គុណភាពស្រូវ

- គុណភាពស្រូវក្រអូបសរីរាង្គ

| ចំណាត់ថ្នាក់ | ភាពសុទ្ធ (%) | កម្រិតសំណើម(%) | អត្រាបាក់(%) |
|---|---|---|---|
| A1( អេ១) | 90%-100% | 13%-14.9% | 01%-24% |
| A2 (អេ២) | 90%-100% | 13%-14.9% | 25%-32% |
| A3 (អេ៣) | 90%-100% | 13%-14.9% | 33%-36% |
| A4(អេ៤) | 90%-100% | 13%-14.9% | 40%-52% |
| AP(អេភី) | 70%-89% | 13%-15.5% | 01-32% |
| B1(ប៊ី១) | 90%-100% | 15%-19.4% | 01%-24% |
| B2(ប៊ី២) | 90%-100% | 15%-19.4% | 25%-36% |
| B3(ប៊ី៣) | 90%-100% | 15%-19.4% | 37%-40% |
| C1(ស៊ី១) | 90%-100% | 19.5%-24.9% | គ្មាន |
| C2(ស៊ី២) | 90%-100% | 25%-30% | គ្មាន |

- គុណភាពស្រូវសរសរីរាង្គ៖

| ចំណាត់ថ្នាក់ | ភាពសុទ្ធ (%) | កម្រិតសំណើម(%) | អត្រាបាក់(%) |
|---|---|---|---|
| D1 (ឌី ១) | 90%-100% | 13%-16% | 1%-16% |
| D2 (ឌី២) | 90%-100% | 13%-16% | 17%-24% |
| D3 (ឌី៣) | 82%-89% | 13%-16% | 1%-24% |
| DM(ឌីអឹម) | 90%-100% | 16.1%-19.5% | គ្មាន |
| DW1(ឌីឌឹប៊ិលយូ១) | 90%-100% | 19.6%-30% | គ្មាន |
| DW2(ឌីឌឹប៊ិលយូ២) | ខុសស្តង់ដាDW1 យកក្នុងកម្រិត២ | | |

***បញ្ជាក់៖ ភាគរយស្រូវរនុកមិនលើសពី៥%

## គ/.ការកំណត់តំលៃស្រូវ

- តម្លៃស្រូវក្រអូបត្រូវកំណត់តាមតម្លៃទីផ្សារជាក់ស្តែងដោយយោងតាមតម្លៃទីផ្សារខ្ពស់បំផុតក្នុងរយៈពេល០៧ថ្ងៃ កន្លងមកដែលបានទិញដោយរោងម៉ាស៊ីនកិនស្រូវធំៗចំនួន០៣កន្លែង នៅក្នុងខេត្ត កំពង់ធំ ឬនិងខេត្តសៀមរាប (ឈ្មោះរោងម៉ាស៊ីនកិនស្រូវអាស្រ័យលើការព្រមព្រៀងដោយភាគី ទាំង ពីរក្នុងកំឡុងពេលប្រមូលផល)។
- តម្លៃស្រូវសរីរាង្គដែលទទួលស្គាល់ដោយអង្គភាពចេញវិញ្ញាបនបត្រ័ពីខាងក្រៅ ត្រូវមានតម្លៃថ្លៃជាងស្រូវក្រអូប ឬស្រូវសរ ធម្មតានៅលើទីផ្សារ។

**តំលៃស្រូវក្រអូបសរីរាង្គ**

| ចំណាត់ថ្នាក់ | តំលៃបុព្វលាភ(រ/គ.ក) |
|---|---|
| A1( អេ១) | 270 |
| A2 (អេ២) | 180 |
| A3 (អេ៣) | 130 |
| A4(អេ៤) | 50 |
| AP(អេភី) | 20 |
| B1(ប៊ី១) | 220 |
| B2(ប៊ី២) | 190 |
| B3(ប៊ី៣) | 130 |
| C1(ស៊ី១) | 180 |
| C2(ស៊ី២) | 160 |

**តំលៃស្រូវស សរីរាង្គ**

| ចំណាត់ថ្នាក់ | តំលៃបុព្វលាភ(រ/គ.ក) |
|---|---|
| D1 (ឌី ១) | 230 |
| D2 (ឌី២) | 190 |
| D3 (ឌី៣) | 130 |
| DM(ឌីអឹម) | 230 |
| DW1(ឌីឌឹបិលយូ១) | 230 |
| DW2(ឌីឌឹបិលយូ២) | 190 |

2. កិច្ចសន្យា ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ រវាងក្រុមហ៊ុន **អាហ្គ្រោ អង្គរ អ៊ីនធើត្រេដ** (Agro Angkor Inter Trade) ជាមួយសហគមន៍កសិកម្មចំនួន០៦ ដើម្បីធ្វើកិច្ចព្រមព្រាងលក់ស្រូវសរាីង្គសរុបចំនួន 7,226.6តោន (ស្រូវក្រអូប 2,383.6តោន , ស្រូវសរ 4,843តោន) មានសមាជិកផលិតចំនួន 1,053គ្រួសារ និងមានផ្ទៃដីផលិតសរុប4,379 ហិចតា។

## ក.តារាងលំអិតតាមសហគមន៍នីមួយៗ៖

| ល.រ | ឈ្មោះសហគមន៍កសិកម្ម | ស្រុក | សមាជិកផលិត (គ្រួសារ) | ផ្ទៃដីសរុប (ហ.ត) | ស្រូវក្រអូប (តោន) | ស្រូវស (តោន) | ចំនួនកិច្ចសន្យា (ត) |
|---|---|---|---|---|---|---|---|
| ១ | រក្សាស្ទឹងសែនមានជ័យ | រវៀង | 239 | 805.5 | 869.3 | 515.2 | 1,384.5 |
| ២ | រស្មីលើកកំពស់កសិករ | រវៀង | 186 | 617.5 | 274 | 702 | 976 |
| ៣ | សាមគ្គីរុងរឿង | រវៀង | 87 | 191 | 167.3 | 82.2 | 249.5 |
| ៤ | រំដោះក្រពុំឈូកសាមគ្គី | រវៀង | 91 | 217.7 | 56 | 243.2 | 299.2 |
| ៥ | លើកកំពស់កសិករ | គូលែន | 276 | 1678.5 | 477.5 | 2,123 | 2,600.5 |
| ៦ | សាមគ្គីភ្នំពេជ្របូរី | គូលែន | 174 | 868.8 | 539.5 | 1,177.4 | 1,716.9 |
| សរុប | | | 1,053 | 4,379 | 2,383.6 | 4,843 | 7,226.6 |

## ខ./គុណភាពស្រូវ

❖ ស្រូវក្រអូប សរីរាង្គ

| គុណភាពស្រូវ | ភាពសុទ្ធ(%) | សំណើម(%) | អត្រាបាក់(%) | ប្រភេទស្រូវ |
|---|---|---|---|---|
| A1( អេ១) | 90%-100% | 13%-14.9% | 1%-24% | ស្រូវរំដួលស្ងួត |
| A2 (អេ២) | 90%-100% | 13%-14.9% | 25%-32% | ស្រូវរំដួលស្ងួត |
| A3 (អេ៣) | 90%-100% | 13%-14.9% | 33%-36% | ស្រូវរំដួលស្ងួត |
| A4(អេ៤) | 90%-100% | 13%-14.9% | 40%-52% | ស្រូវរំដួលស្ងួត |
| PR-L | 70%-89% | 13%-15.5% | 1-32% | ស្រូវរំដួលស្ងួត |
| B1(ប៊ី១) | 90%-100% | 15%-19.4% | 1%-24% | ស្រូវរំដួលស្រពាប់ |
| B2(ប៊ី២) | 90%-100% | 15%-19.4% | 25%-36% | ស្រូវរំដួលស្រពាប់ |
| B3(ប៊ី៣) | 90%-100% | 15%-19.4% | 37%-40% | ស្រូវរំដួលស្រពាប់ |
| C1(ស៊ី១) | 90%-100% | 19.5%-24.9% | គ្មាន | ស្រូវរំដួលសើម |
| C2(ស៊ី២) | 90%-100% | 25%-30% | គ្មាន | ស្រូវរំដួលសើម |

❖ ស្រូវ-ស សរីរាង្គ

| | | | | |
|---|---|---|---|---|
| D1 (ដេ ១) | 90%-100% | 13%-16% | 1%-16% | ស្រូវ-ស ស្ងួត |
| D2(ដេ ២) | 90%-100% | 13%-16% | 17%-2 4% | ស្រូវ-ស ស្ងួត |
| D3(ដេ៣) | 82%-89% | 13%-16% | 1%-24% | ស្រូវ-ស ស្ងួត |
| DM | 90%-100% | 16.1%-19.5% | 1%-16% | ស្រូវ-ស ស្រពាប់ |
| DW1 | 90%-100% | 19.6%-៣0% | 1%-16% | ស្រូវ-ស សើម |
| DW2 | ខុសស្តង់ដា DW-1 ជួយយកក្នុងកម្រិតលេខ ២ | | | ស្រូវ-ស សើម |

## គ./លក្ខខណ្ឌកំណត់តម្លៃស្រូវ

- តម្លៃស្រូវ **គោល** កំណត់តាមតម្លៃទីផ្សារជាក់ស្តែង ដោយយោងតាមតម្លៃទីផ្សារ ក្នុងរយៈពេល ៧ ថ្ងៃកន្លងមក ដែលបានទិញដោយរោងម៉ាស៊ីនកិនស្រូវធំៗចំនួន០៣ កន្លែង (រោងម៉ាស៊ីន១ នៅព្រះវិហារ និង២នៅកំពង់ធំ) ដែលព្រមព្រៀងដោយភាគីទាំងពីរ។

- តម្លៃស្រូវសរីរាង្គដែលទទួលស្គាល់ដោយស្ថាប័ន ចេញវិញ្ញាបនបត្រពីខាងក្រៅស្របតាមស្តង់ដារអន្តរជាតិ (EOS និង NOP) ត្រូវមានតម្លៃបុព្វលាភបន្ថែមដែលមាន កំណត់ក្នុងតារាងខាងក្រោម:

❖ **តម្លៃស្រូវសរីរាង្គ**

| គុណភាពស្រូវរំដួល | ថ្លៃបុព្វលាភ 2018 | គុណភាពស្រូវ-ស | ថ្លៃបុព្វលាភ 2018 |
|---|---|---|---|
| A1( អេ១) | 260 | D1 (ដេ ១) | 220 |
| A2 (អេ២) | 170 | D2(ដេ ២) | 180 |
| A3 (អេ៣) | 120 | D3(ដេ៣) | 120 |
| A4(អេ៤) | 40 | DM | 230 |
| PR-L | 10 | DW1 | 230 |
| B1(ប៊ី១) | 210 | DW2 | 200 |
| B2(ប៊ី២) | 180 | | |
| B3(ប៊ី៣) | 120 | | |
| C1(ស៊ី១) | 170 | | |
| C2(ស៊ី២) | 150 | | |

រាល់ស្រូវ-ស ខាងលើ អង្ករ **រនុក** ក្រហមមិនលើសពី ៥ %

3. កិច្ចសន្យា ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ រវាងក្រុមហ៊ុន **ស៊ិកនេឈ័រ អហ្ស អេស៊ា** (Signatures of Asia) ជាមួយសហគមន៍កសិកម្មចំនួន០៨ ដើម្បីធ្វើកិច្ចព្រមព្រៀងលក់ស្រូវសរីរាង្គសរុបចំនួន 3,548.2 តោន (ស្រូវក្រអូប494.8តោន, ស្រូវសរ 3,053.4តោន) មានសមាជិកផលិតចំនួន 1,067គ្រួសារ និងមានផ្ទៃដីផលិតសរុប1,843.2ហិចតា។

### ក.តារាងលំអិតតាមសហគមន៍នីមួយៗៈ

| ល.រ | ឈ្មោះសហគមន៍កសិកម្ម | ស្រុក | សមាជិកផលិត (គ្រួសារ) | ផ្ទៃដីសរុប (ហ.ត) | ស្រូវក្រអូប (តោន) | ស្រូវស (តោន) | ចំនួនកិច្ចសន្យា (ត) |
|---|---|---|---|---|---|---|---|
| ១ | ប្រាច់សាលវន្តសាមគ្គីសែនជ័យសែនជ័យ | ជ័យសែន | 177 | 244 | 70.50 | 359.3 | 428.8 |
| ២ | ខ្យងស័ងសាមគ្គី | ជ័យសែន | 104 | 245.8 | 129.7 | 443.2 | 572.9 |
| ៣ | ពុទ្រាសាមគ្គីវឌ្ឍនៈមានជ័យ | ជ័យសែន | 297 | 513.4 | 21.6 | 936.3 | 957.9 |
| ៤ | ផ្លាណាទ្បាគីរីសាមគ្គីសែនជ័យ | ជ័យសែន | 66 | 77.4 | 37 | 176.45 | 213.45 |
| ៥ | សាមគ្គីសុវណ្ណគីរីឆែប | ឆែប | 55 | 65.5 | 11 | 84.4 | 95.4 |
| ៦ | អភិវឌ្ឍន៍សង្កែពី | ឆែប | 159 | 232.7 | 68.9 | 371.25 | 440.15 |
| ៧ | រំដួលសាមគ្គីមានជ័យម្លូព្រៃពីរ | ឆែប | 133 | 348.9 | 101.6 | 538.2 | 639.8 |
| ៨ | សង្កែសាមគ្គីមានជ័យ | ឆែប | 76 | 115.5 | 54.5 | 144.3 | 199.8 |
| សរុប | | | 1,067 | 1,843.2 | 494.8 | 3,053.4 | 3,548.2 |

**ខ/.គុណភាពស្រូវ:**

| ប្រភេទគុណភាពស្រូវ | គ្រាប់ស្រូវខូច(%) | កម្រិតសំណើម(%) | សំរាម(%) | ភាពសុទ្ធ(%) | អត្រា(%) | សណ្ដី(%) |
|---|---|---|---|---|---|---|
| លេខ១ | ≤ 2 | ≤ 15 | ≤ 0.5 | ≥ 90 | ≤ 10 | ≤ 0.5 |
| លេខ១ | ≤ 3 | ≤ 15 | ≤ 0.5 | ≥ 90 | >10-16 | >0.5-1 |
| លេខ១ | ≤ 4 | ≤ 15 | ≤ 0.5 | 85 - <90 | >16-25 | >1-2 |
| លេខ១ | ≤ 5 | ≤ 15 | > 0.5 - 1 | 85 - <90 | >25-35 | >2-3 |
| លេខ១ | ≤ 6 | ≤ 15 | > 0.5 - 1 | 85 - <90 | >35-45 | >3-4 |

**គ/.ការកំណត់តំលៃស្រូវ**

- តម្លៃស្រូវ គោល កំណត់តាមតម្លៃទីផ្សារជាក់ស្តែង ដោយយោងតាមតម្លៃទីផ្សារ ក្នុងរយៈពេល ៧ ថ្ងៃកន្លងមក ដែលបានទិញដោយរោងម៉ាស៊ីនកិនស្រូវធំៗចំនួន០៣ កន្លែង (រោងម៉ាស៊ីន១ នៅព្រះវិហារ និង២នៅកំពង់ធំ) ដែលព្រមព្រៀងដោយភាគីទាំងពីរ។
- តម្លៃស្រូវសរីរាង្គដែលទទួលស្គាល់ដោយអង្គភាពចេញវិញ្ញាបនបត្រ័ពីខាងក្រៅ ត្រូវមានតម្លៃថ្លៃជាងស្រូវក្រអូប ឬស្រូវសរ ធម្មតានៅលើទីផ្សារ។
  - តម្លៃស្រូវសរសរីរាង្គ

| ចំណាត់ថ្នាក់ | តំលៃបុព្វលាភ ២០១៨ (រ/គ.ក) |
|---|---|
| លេខ១ | 300 |
| លេខ១ | 275 |
| លេខ១ | 250 |
| លេខ១ | 225 |
| លេខ១ | 200 |

4. កិច្ចសន្យា ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ រវាងក្រុមហ៊ុន **សាជីវកម្មសហគមន៍កសិកម្មកម្ពុជា(CACC)** ជាមួយសហគមន៍កសិកម្មចំនួន០១ គឺសហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ ដើម្បីធ្វើកិច្ចព្រមព្រៀងលក់ស្រូវសរីរាង្គសរុបចំនួន 1,040 តោន (ស្រូវក្រអូប**201**តោន, ស្រូវសរ 839តោន) មានសមាជិកផលិតចំនួន 185គ្រួសារ និងមានផ្ទៃដីផលិតសរុប 681ហិចតា។

**ក./គុណភាពស្រូវ:**

❖ **ស្រូវក្រអូប សរីរាង្គ**

| គុណភាពស្រូវ | ភាពសុទ្ធ(%) | សំណើម(%) | អត្រាបាក់(%) | ប្រភេទស្រូវ |
|---|---|---|---|---|
| A1( អេ១) | 90%-100% | 13%-14.9% | 1%-24% | ស្រូវរំដួលស្ងួត |
| A2 (អេ២) | 90%-100% | 13%-14.9% | 25%-32% | ស្រូវរំដួលស្ងួត |

| | | | | |
|---|---|---|---|---|
| A3 (អេ៣) | 90%-100% | 13%-14.9% | 33%-36% | ស្រូវរំដួលស្អូត |
| A4(អេ៤) | 90%-100% | 13%-14.9% | 40%-52% | ស្រូវរំដួលស្អូត |
| PR-L | 70%-89% | 13%-15.5% | 1-32% | ស្រូវរំដួលស្អូត |
| B1(ប៊ី១) | 90%-100% | 15%-19.4% | 1%-24% | ស្រូវរំដួលស្រពាប់ |
| B2(ប៊ី២) | 90%-100% | 15%-19.4% | 25%-36% | ស្រូវរំដួលស្រពាប់ |
| B3(ប៊ី៣) | 90%-100% | 15%-19.4% | 37%-40% | ស្រូវរំដួលស្រពាប់ |
| C1(ស៊ី១) | 90%-100% | 19.5%-24.9% | គ្មាន | ស្រូវរំដួលសើម |
| C2(ស៊ី២) | 90%-100% | 25%-30% | គ្មាន | ស្រូវរំដួលសើម |

❖ **ស្រូវ-ស សរីរាង្គ**

| | | | | |
|---|---|---|---|---|
| D1 (ដេ ១) | 90%-100% | 13%-16% | 1%-16% | ស្រូវ-ស ស្អូត |
| D2(ដេ ២) | 90%-100% | 13%-16% | 17%-2 4% | ស្រូវ-ស ស្អូត |
| D3(ដេ៣) | 82%-89% | 13%-16% | 1%-24% | ស្រូវ-ស ស្អូត |
| DM | 90%-100% | 16.1%-19.5% | 1%-16% | ស្រូវ-ស ស្រពាប់ |
| DW1 | 90%-100% | 19.6%-៣0% | 1%-16% | ស្រូវ-ស សើម |
| DW2 | ខុសស្តង់ដា DW-1 ជួយយកក្នុងកម្រិតលេខ ២ | | | ស្រូវ-ស សើម |

**ខ/.ការកំណត់តំលៃស្រូវ**

- តម្លៃស្រូវ **គោល** កំណត់តាមតម្លៃទីផ្សារជាក់ស្តែង ដោយយោងតាមតម្លៃទីផ្សារ ក្នុងរយៈពេល ៧ ថ្ងៃកន្លងមក ដែលបានទិញដោយរោងម៉ាស៊ីនកិនស្រូវធំៗចំនួន០៣ កន្លែង (រោងម៉ាស៊ីន១ នៅព្រះវិហារ និង២នៅកំពង់ធំ) ដែលព្រមព្រៀងដោយភាគីទាំងពីរ។
- តម្លៃស្រូវសរីរាង្គដែលទទួលស្គាល់ដោយស្ថាប័ន ចេញវិញ្ញាបនបត្រពីខាងក្រៅស្របតាមស្តង់ដារអន្តរជាតិ (EOS និង NOP) ត្រូវមានតម្លៃបុព្វលាភបន្ថែមដែលមាន កំណត់ក្នុងតារាងខាងក្រោមៈ

❖ **តម្លៃស្រូវសរីរាង្គ**

| គុណភាពស្រូវរំដួល | ថ្លៃបុព្វលាភ 2018 | | គុណភាពស្រូវ-ស | ថ្លៃបុព្វលាភ 2018 |
|---|---|---|---|---|
| A1( អេ១) | 260 | | D1 (ដេ ១) | 220 |
| A2 (អេ២) | 170 | | D2(ដេ ២) | 180 |

| | | | | |
|---|---|---|---|---|
| A3 (អេ៣) | 120 | | D3(ដេ៣) | 120 |
| A4(អេ៤) | 40 | | DM | 230 |
| PR-L | 10 | | DW1 | 230 |
| B1(ប៊ី១) | 210 | | DW2 | 200 |
| B2(ប៊ី២) | 180 | | | |
| B3(ប៊ី៣) | 120 | | | |
| C1(ស៊ី១) | 170 | | | |
| C2(ស៊ី២) | 150 | | | |

រាល់ស្រូវ-ស ខាងលើ អង្ករ **រនុក** ក្រហមមិនលើសពី ៥ %

II. <u>ខ្លឹមសារសំខាន់ៗនៅក្នុងកិច្ចសន្យាផលិត និងផ្គត់ផ្គង់ដំឡូងមីសរីរាង្គមានដូចខាងក្រោម៖</u>

1. កិច្ចសន្យា ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ រវាងក្រុមហ៊ុន **សាជីវកម្មសហគមន៍កសិកម្មកម្ពុជា(CACC)** ជាមួយសហគមន៍កសិកម្មចំនួន០៨ ដើម្បីធ្វើកិច្ចព្រមព្រៀងលក់ដំឡូងមីសរីរាង្គសរុបចំនួន 10,748តោន មានសមាជិកផលិតចំនួន 577គ្រួសារ និមានផ្ទៃដីផលិតសរុប 789.01ហិចតា។

**<u>ក.តារាងលំអិតតាមសហគមន៍នីមួយៗ៖</u>**

| ល.រ | ឈ្មោះសហគមន៍ | ស្រុក | ចំនួនអ្នកផលិត (គ្រួសារ) | ផ្ទៃដីផលិត (ហ.ត) | កិច្ចសន្យាលក់ (តោន) |
|---|---|---|---|---|---|
| ១ | ក្របៅព្រហ្មទេព | គូលែន | 63 | 94 | 1,755 |
| ២ | សាមគ្គីភ្នំពេជ្របូរី | គូលែន | 87 | 122.90 | 1,210 |
| ៣ | លើកកំពស់កសិករ | គូលែន | 91 | 163 | 2,445 |
| ៤ | ត្បែងពីរសាមគ្គីរីកចំរើន | គូលែន | 71 | 114 | 1,379 |
| ៥ | ទឹកក្រហមកែលំអរជីវភាព | ជាំក្សាន្ត | 30 | 43 | 417 |
| ៦ | ជាំក្សាន្តជាយដែនមានជ័យ | ជាំក្សាន្ត | 110 | 137 | 1,879 |
| ៧ | រំដោះស្រែសាមគ្គី | ជាំក្សាន្ត | 84 | 72.70 | 744.00 |
| ៨ | សាមគ្គីសង្កែពីរ | ឆែប | 41 | 41.65 | 919 |
| សរុប | | | 577 | 789.01 | 10,748 |

**ខ./គុណភាពដំឡូងមី**

- ភាគីទាំងពីរ ឯកភាពគាពិនិត្យគុណភាពផលិតផលជាក់ស្តែងនៅកន្លែងប្រមូលលក់ទិញ
- ជាផលិតផលដំឡូងមីសរីរាងស្រស់ ប្រមូលផលទុកមិនលេលស ៤៨ម៉ោង (ប្រមូលផលថ្ងៃនេះ ថ្ងៃស្អែកក្រុមហ៊ុនប្រមូលទិញ និងដឹកចេញ)។
- ការខូចខាត (គឹងស៊ី សំបុរស្រអាប់ ខ្មៅ ឬជាំ និងស្អុយយ...) មិនលេលសចំនួន ១០%
- ការជាប់ដី ឬជាប់ខ្មែង ជាប់នឹងទងមើម មិនលេលសចំនួន ០២% (ពីរភាគរយ)។

## គ./លក្ខខណ្ឌកំណត់តម្លៃស្រូវ

- ភាគីទាំងពីរបានឯកភាពគា  សិក្សាតំលៃដំឡូងមីតាមកន្លែងប្រមូលទិញធំៗក្នុងស្រុក  ចំនួន០៣ កន្លែង ដោយប្រើរយៈពេលសិក្សាពី០១ ទៅ ០២សប្តាហ៍ មុនកាប្រមូលផល និងពី០៣ ទៅ ០៧ថ្ងៃ ត្រូវសិក្សាតម្លៃម្តង។  អ្នកសិក្សាតម្លៃគឺក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម  និងតំណាងក្រុមហ៊ុន ត្រូវឯកភាពក្នុងតម្លៃគោលក្រោយ។
- ភាគីអ្នកទិញនឹងបន្ថែម  តម្លៃបន្ថែម(បុព្វលាភ)  ទៅឲ្យភាគីអកផលិតចំនួន  ២០%  (ម្តៃភាគរយ) ក្នុងទំងន់ដំឡូងម្រីសស់មួយគីឡូក្រាម (០១គ.ក្រ)។

**តារាងប្រៀបធៀបកិច្ចសន្យាស្រូវសរីរាង្គតាមឆ្នាំនីមួយៗ**

| ឆ្នាំ | ចំនួនសហគមន៍ | កសិករផលិត (គ្រួសារ) | ផ្ទៃដីផលិត (ហិកតា) | កិច្ចសន្យា (តោន) | លក់បាន ជាក់ស្តែង(តោន) | ភាគរយ (%) |
|---|---|---|---|---|---|---|
| 2014 | 8 | 891 | 2,293 | 1,800 | 1,465.67 | 81.43 |
| 2015 | 12 | 1,669 | 4,184.9 | 8,665.65 | 2,790.05 | 32.20 |
| 2016 | 25 | 3,151 | 8,702.65 | 13,795.35 | 11,476.13 | 83.19 |
| 2017 | 32 | 5,162 | 15,811.7 | 26,538.19 | 13,984.11 | 52.70 |
| 2018 | 32 | 5,053 | 16,052.01 | 26,786.25 | - | - |









ថ្ងៃអង្គារ ៤រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២
ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨
ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម

**បានឃើញ និងឯកភាព**
ថ្ងៃអង្គារ ៤រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២
ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨
**ប្រធានមន្ទីរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ
ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម

# របាយការណ៍
# ស្ដីពីការចុះកិច្ចសន្យាផលិតកម្មកសិកម្ម(CONTRACT FARMING)
# ផលិតនិងផ្គត់ផ្គង់ស្រូវ និងដំឡូងមី សរីរាង្គរវាងសហគមន៍កសិកម្មក្នុងខេត្តព្រះវិហារ
# ជាមួយក្រុមហ៊ុនឯកជន ឆ្នាំ២០១៨






ព្រះវិហារ,ខែកក្កដា ឆ្នាំ២០១៨

# កម្រងរូបភាពសកម្មភាពដំណើរការចុះកិច្ចសន្យា ដែលមានការគាំទ្រពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ
























